# អវកាស ទទេ

**Espace vide**

យុទ្ធសាស្ត្រ របស់វៀតណាម ពាក់ព័ន្ធនឹង ស្រុកខ្មែរ តាំងពី ឆ្នាំ ១៩៧៩ មក គឺ ទុក ស្រុកខ្មែរ ជា អវកាស ទទេ។ នៅក្នុង អវកាសនោះ គេប្រដិឌ ទ្រឹស្តី ថា ស្រុកខ្មែរ ជា ស្រុកមាន ពហុ ជាតិសាសន៍ តាំងពីកំណើត មក ហើយ ជាតិសាសន៍ខ្មែរ ក្រាន់ តែជា សមាសភាពមួយ ក្នុង ចំណោមជាតិសាសន៍ដ៏ទៃ។ ដូច នេះ គេបង្កើត អត្តសញ្ញាណថ្មី សំរាប់ប្រជាជន រស់នៅលើទឹក ដីខ្មែរ គឺ ‹ប្រជាជន កម្ពុជា› ដែលជា ការប្រមូលរួម (collection) នៃ ជនជាតិផ្សេងៗ គឺមាន ខ្មែរ, យួន, ចិន, ចាម, ជនជាតិភ្នំ ។ល។

ទ្រឹស្តីនេះ គឺ ជា ការលុបបំបាត់ អត្តសញ្ញាណខ្មែរ ជា ប្រជាជាតិ មាន ឫសគល់ ពិតប្រាកដ ហើយ កសាង អរិយធម៌, ប្រវត្តិសា ស្ត្រខ្លួន ដោយ អត្តពោលអះអាង[1] នូវ អត្តភាពពិត របស់ខ្លួន ចំពោះអ្នកដទៃ។ ដូចនេះ ប្រជាពលរដ្ឋខ្មែរ មិនមែនជា ការ ប្រមូលរួម នៃ បុគ្គល ឬ ជាតិសាសន៍ នោះទ្បើយ គឺជា ព្រលឹង ជាតិ មាន ក្រឹះ ជា តម្លៃ ដែលមាននៅក្នុងខ្លួន[2] កើតចេញពី

[1] អត្តពោលអះអាង ជា ពាក្យខ្ញុំយកមកប្រើដើម្បីសំរួលការសរសេរ ដែលមានន័យ ពាក្យបារាំងថា s'affirmer។
[2] តម្លៃ ដែលមាននៅក្នុងខ្លួន ; valeur intrinsèque។

## អវកាស ទទេ

អភិក្រម នៃ ការបង្កើត[3] នៃ អរិយធម៌ និង វប្បធម៌ មួយ ដ៏យូរ អង្វែង។

ទ្រឹស្តី របស់ឃួននេះ ត្រូវ របប ដឹកនាំនៅស្រុកខ្មែរសព្វថ្ងៃ គេ យកមកធ្វើជារបស់ខ្លួន ក្នុងនាម សន្តិភាព ហើយ ពួកអ្នក ដឹកនាំ គណបក្សប្រឆាំង ចូលរួម អនុវត្ត ទាំងស្រុង ក្នុងនាម ជា អ្នក មិនប្រកាន់ពូជសាសន៍ ឬ ភតិបណ្ឌិត (le sage)។ តាម ការពិត ទ្រឹស្តី នោះ មាន ជារមី នៅស្រុកខ្មែរ គឺដោយសារ ប្រជា ពលរដ្ឋខ្មែរ សូម ចុះចាញ់ តែម្តង នៅចំពោះមុខ អំណាចឃួន នៅស្រុកខ្មែរ ក្នុងនាម នៃ កំនិត កម្មផល រឿ កំនិត ស្លូត របស់ ពួកអ្នកដឹកនាំ គណបក្សប្រឆាំង និង ចាគប័ត្រ[4] នៃ ពួកអ្នក ចេះដឹងខ្មែរ វិញ វាមាន នយ ដូច បុរាណភាសិតខ្មែរ ថា ‹មនុស្ស ស្លូតស្លាប់› សូមចាញ់មារ មិនតវ៉ា។ ដូចនេះ ប្រជាជាតិខ្មែរ សព្ព ថ្ងៃ មាន សភាព ជា ប្រជាជាតិ បិតនៅក្នុង អវកាស ទទេ ដែល នៅក្នុងនោះ គេអាចយក វត្ថុធាតុ អ្វីគ្រប់បែបយ៉ាង មកដាក់ ក៏បានដែរ។ ការចុះចាញ់នោះ រុញ អភិក្រម នៃ ការលុបបំបាត់ អត្តសញ្ញាណ សហស្សវត្ស រៀ របស់ប្រជាជាតិខ្មែរ អោយ កាន់តែ លឿនឡើង ហើយ បង្កើតជា អវកាស ទទេ នៅ ស្រុកខ្មែរថ្មី អោ យកាន់តែ ធំសែនទ្វី សំរាប់កសាង មហាវៀតណាម។ ម្លោះហើយ អត្តសញ្ញាណខ្មែរថ្មី គឺ ជា ជាតិសាសន៍ ភាគតិចមួយ នៅ តណ្ឌូចិន ឃួនបនីយកម្ម គឺថា ជាតិសាសន៍ខ្មែរ វាគ្រាន់តែ ស្ថិត

---

[3] អភិក្រម នៃ ការបង្កើត ; processus de formation។

[4] ចាគប័ត្រ, ការបោះបង់សិទ្ធរបស់ខ្លួនអោយអ្នកដទៃ; résignation។

## អវកាស ទទេ

នៅក្នុង ការបង្កើត ជាធម្មជាតិ នៃប្រជាជាតិយួន ក្នុងការវិវត្ត ន៍ នៃមនុស្សជាតិ តែប៉ុណ្ណោះ។

ទ្រឹស្តី នៃ អវកាស ទទេ នោះ អាចនាំអោយ រៀតណាម មិន គ្រាន់តែ ប្លន់យក ទឹកដីខ្មែរបាន តាម កម្លាំងយោធា នោះ ឡើយ គឺ គេអាច ប្តូរ អត្តសញ្ញាណខ្មែរ តាម កម្លាំងបញ្ញា ថែម ទៀត។ ប្រវត្តិសាស្ត្រ អបរភាព របស់ខ្មែរ ក្នុង ទស្សនបថ នៃ ពិភពលោក[5] គឺ គ្រាន់តែជារឿងបន្ទាប់បន្សំ នៅក្នុង ប្រវត្តិសា ស្ត្រ នៃ ប្រជាជាតិរៀតណាម តែប៉ុណ្ណោះ ព្រោះ រៀតណាម ប្រើ គ្រប់មយោបាយ ដើម្បីអោយ ប្រវត្តិសាស្ត្រ នោះ កើតឡើងបាន ហើយ ចំណេរតមក ទស្សនបថ នៃ ពិភពលោកនោះ ក្លាយជា ការពិត សំរាប់យុវជនកម្ពុជា។ ម្លោះហើយ ក្នុង អនាគតដ៏ខ្លី ទឹកដីខ្មែរ សព្វថ្ងៃ ក្លាយជា ទឹកដី បុព្វបុរសយួន សំរាប់យុវជន យួន ដូច កម្ពុជាក្រោម នោះដែរ។

នៅក្នុង បរិបទ នេះ ពួក ចិត្តបណ្ឌិត (penseurs) ខ្មែរ មួយ ចំនួនធំ ដែលមានការដាស់តឿន ពីបញ្ហាជាតិ នាំគ្នាទៅពួន ក្នុងទីជ្រក នៃ ផាសុកភាព នៃបញ្ញា[6] គឺ គំនិតអហិង្សា នៅ ចំពោះមុខគ្រប់បញ្ហាជាតិ។ គំនិតនេះ គឺ ជា អវកាស ទទេ ដែល យួន ជាអ្នក បង្កើត នោះឯង॥

---

[5] ប្រវត្តិសាស្ត្រ អបរភាព របស់ខ្មែរ ក្នុង ទស្សនបថ នៃពិភពលោក ; l'histoire khmère dans le futur dans le champ de vision mondiale។

[6] ផាសុកភាព នៃបញ្ញា ; confort intellectuel។